ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៦៣៨/០១-៩-២០០៥

សាលដីកា

លេខ:៩៧(ជ)/០៧-៩-២០០៧

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី០៧-៩-២០០៧ ដែលមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៦៣៨ ចុះថ្ងៃទី០១-៩-២០០៥ រវាង៖

-ជនជាប់ចោទឈ្មោះ សោម រី ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ កើតនៅភូមិបាសាក់ ឃុំបាសាក់ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅសព្វថ្ងៃ [redacted] ស្វាយជ្រុំ ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] សាម៉ុន(រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។ ឃុំខ្លួនថ្ងៃទី២៧.៥.២០០៥ ។ នៅពន្ធនាគារខេត្តស្វាយរៀង

មេធាវីការពារឈ្មោះ [redacted] សារី

ត្រូវចោទពីបទ:រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិបាសាក់ ឃុំបាសាក់ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង កាលពីថ្ងៃទី០៥-០២-២០០១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណី និង ជាជនរងគ្រោះឈ្មោះ [redacted] សាមឌន ភេទប្រុស អាយុ៣២ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃ [redacted] ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ។

១៣០

## ឯរឿងហេតុមានដូចតទៅ

តាមពាក្យបណ្តឹងចុះថ្ងៃទី០៧.០២.២០០១ របស់ឈ្មោះ [redacted] សាមន ជាជនរងគ្រោះ បានប្តឹងពីឈ្មោះ [redacted] សារី អាយុ២០ឆ្នាំ ភេទប្រុស ដែលបានចាប់ខ្លួនរំលោភបង្ខំសេពសន្ថវៈ រហូតបានសម្រេចបំណង កាលពីថ្ងៃទី០៥.០២.២០០១ វេលាប្រហែលម៉ោង១០យប់ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ:៧៤ ចុះថ្ងៃទី១៦-៧-២០០២ របស់សាលាដំបូងខេត្តស្វាយរៀង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] រី ដាក់ពន្ធនាគារកំណត់០៨(ប្រាំបី)ឆ្នាំ គិតពីថ្ងៃចាប់ឃុំខ្លួន ពីបទ:រំលោភសេពសន្ថវៈលើស្ត្រីភេទ ប្រព្រឹត្តនៅភូមិបាសាក់ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង កាលពីយប់ថ្ងៃទី០៥-០២-២០០១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ឲ្យឈ្មោះ [redacted] រី សងសំណងជម្ងឺចិត្តជាប្រាក់ចំនួន១០០០០០០(មួយលាន)រៀល ឲ្យទៅឈ្មោះនារី [redacted] សាមន ជាជនរងគ្រោះ និង ជាដើមបណ្តឹងរដ្ឋប្បវេណី ។ សំណើលើសពីនេះត្រូវលើកចោល ។

បើពុំមានប្រាក់សងគ្រប់ចំនួនទេ ត្រូវអនុវត្តតាមមាត្រា៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ គឺ $\frac{\text{១ថ្ងៃគុណនឹង១០០០០០}}{\text{៥០០}}$ ស្មើនឹង២០០ថ្ងៃ និង $\frac{\text{១ថ្ងៃគុណនឹង៩០០០០០}}{\text{១០០០}}$ ស្មើនឹង៩០០ថ្ងៃ បន្ថែមទៀត បូករួមចំនួន១,១០០ថ្ងៃ(តែការដាក់គុកនេះមិនឲ្យលើសពីកំណត់ច្បាប់ឡើយ) ។

៣-សាលក្រមនេះជំនុំជម្រះជាការសម្ងាត់ និង ប្រកាសជាសាធារណ: ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខឈ្មោះ [redacted] រី បើកផ្លូវប្តឹងទាស់ និង បើកផ្លូវឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី២០-៦-២០០៧ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញសេចក្តីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាសង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] រី (អវត្តមាន)

-មេធាវីលោក [redacted]សារី (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាមន (អវត្តមាន)

-តំណាងមហាអយ្យការសន្និដ្ឋានថា: ជនជាប់ចោទពិតជាបានរំលោភលើជនរងគ្រោះពិតប្រាកដមែន សូមតម្កល់សាលក្រមព្រហ្មទណ្ឌលេខ:៧៤ ចុះថ្ងៃទី១៦.៧.២០០២ របស់តុលាការខេត្តស្វាយរៀង ទុកជាបានការដដែល ។

១៣១

-មេធាវីលោក [redacted] សារី ការពារឲ្យជនជាប់ចោទសន្និដ្ឋានថា: រឿងក្តីនេះកូនក្តីខ្លួនមិនប្រព្រឹត្តដូចការចោទប្រកាន់របស់ជនរងគ្រោះទេ ហើយជនរងគ្រោះក៏មិនបានពិនិត្យនៅមន្ទីរពេទ្យត្រឹមត្រូវទេ សូមក្រុមប្រឹក្សាជំនុំជម្រះលើកលែងចោទប្រកាន់ ដល់កូនក្តីខ្លួនឲ្យមានសេរីភាព ។

-ក្រោយពីបានអានរបាយការណ៍

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍

## យល់ឃើញថា ៖

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០១.៨.២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] រី ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមបញ្ញត្តិមាត្រា១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២-តាមចម្លើយជនរងគ្រោះ [redacted] សាម៉ន ម្តាយជនរងគ្រោះ [redacted] មៀច និងមេភូមិ [redacted] ទិត បញ្ជាក់ថាឈ្មោះ [redacted] រី បានរំលោភសេពសន្ថវៈលើឈ្មោ [redacted] សាម៉ន កាលពីយប់ថ្ងៃ០៥.២.២០០១ មែន ។

៣-តាមពាក្យសុំដកបណ្តឹងចុះថ្ងៃទី២៦.០១.២០០៧ ឈ្មោះ [redacted] សាមន បានសុំឲ្យជនល្មើស [redacted] រី រួចពីការចោទប្រកាន់ និង សុំដោះលែងឲ្យមានសេរីភាពវិញ ។ ឃើញថាពាក្យសុំនេះរលត់តែសំណងរដ្ឋប្បវេណីប៉ុណ្ណោះ ឯបណ្តឹងអាជ្ញាពុំអាចរលត់បានឡើយ ។

៤-ជនជាប់ចោទជាអនីតិជនអាយុ១៧ឆ្នាំ គប្បីទទួលបានស្ថានសម្រាលទោស តាមមាត្រា៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង តាមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ។

៥-សាលក្រមព្រហ្មទណ្ឌលេខៈ៧៤ ចុះថ្ងៃទី១៦.៧.២០០២ របស់តុលាការខេត្តស្វាយរៀង មានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ វៀរលែងតែការផ្តន្ទាទោសលើឈ្មោះ [redacted] រី ត្រូវកែប្រែតាមការយល់ឃើញខាងលើ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] រី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ៧៤ ចុះថ្ងៃទី១៦.៧.២០០២ របស់តុលាការខេត្តស្វាយរៀង ទុកជាបានការ វៀរលែងតែការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] រី ត្រង់ចំណុចទី១ ត្រូវកែប្រែពី៨ឆ្នាំមកជា២ឆ្នាំ៦ខែ គិតពីថ្ងៃចាប់ខ្លួន ២៧.៥.២០០៥ វិញ តាមមាត្រា៣៣ និង ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១៣២

៣-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹង ។

បើកផ្លូវប្តឹងតវ៉ា តាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្ត សាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការ អនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ១៧ ខែ ៣ ឆ្នាំ ២០១៤

| | |
|---|---|
| បានឃើញ | |
| ប្រធានសាលាឧទ្ធរណ៍ | ក្រឡាបញ្ជី |
| [redacted] | [redacted] |

១៣៣